ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ជំនួបសំណេះសំណាលរវាងឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
## ជាមួយនិស្សិតកម្ពុជាដែលប្រឡងជាប់ក្របខ័ណ្ឌអាហារូបករណ៍អាស៊ាន-នូវែលហ្សេឡង់

*********

នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ វេលាម៉ោង១៦:០០នាទី ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតអោយនិស្សិតកម្ពុជាដែលប្រឡងជាប់អាហារូបករណ៍ក្របខ័ណ្ឌអាស៊ាន-នូវែលហ្សេឡង់ ចំនួន២៧នាក់ (ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់២៥នាក់ និងថ្នាក់បណ្ឌិត២នាក់) ដែលត្រូវចេញសិក្សានៅប្រទេសណូវែលហ្សេឡង់ក្នុងឆ្នាំ ២០១៧ នេះ ចូលជួបសម្តែងការគួរសម។

ក្នុងចំណោមនិស្សិតចំនួន២៧**នាក់**នេះ គឺមាន៨នាក់មកពីស្ថាប័នរដ្ឋ ចំនួន១១នាក់មកពីវិស័យឯកជន និងចំនួន៨នាក់មកពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ មុខវិជ្ជាដែលត្រូវសិក្សា រួមមាន នយោបាយសាធារណៈ គណនេយ្យ និងហិរញ្ញវត្ថុ សេដ្ឋកិច្ច ច្បាប់ សុខាភិបាល ទំនាក់ទំនងអន្តរជាតិ គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ពន្ធដារ និង e-government ជាដើម។

ថ្លែងក្នុងពិធីសំណេះសំណាល **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការអបអរសាទរចំពោះនិស្សិតទាំង២៧នាក់ ដែលប្រឡងជាប់អាហារូបករណ៍សំរាប់ការសិក្សានៅប្រទេសនូវែលហ្សេឡង់ក្នុងឆ្នាំ២០១៧ នេះ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានចែករំលែកជូននិស្សិតដែលត្រូវចេញសិក្សាទាំងអស់នោះ នូវបទពិសោធន៍ផ្ទាល់ខ្លួនរបស់ឯកឧត្តម ក្នុងឋានៈជាកូនក្នុងគ្រួសារអ្នកការទូត ដែលធ្លាប់បានឆ្លងកាត់ដំណាក់កាលត្រូវចាកចេញពីគ្រួសារនិងមាតុប្រទេស ដើម្បីទៅធ្វើការសិក្សា និងអំពីការលំបាកផ្សេងៗដែលត្រូវជួបប្រទះនៅក្នុងអំឡុងពេលរស់នៅដោយខ្លួនឯង និងបំពេញការសិក្សានោះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានណែនាំដល់និស្សិតទាំង២៧រូប ត្រៀមលក្ខណៈអោយបានល្អ ព្រោះការទៅសិក្សានៅបរទេសនឹងមានការប្រឈមមិនបានគ្រោងទុក ដែលអាចកើតមានឡើងលើជីវភាព ម្ហូបអាហារ ធាតុអាកាស និងទំនៀមទំលាប់ ដែលខុសពីទំនៀមទំលាប់របស់យើង។ **ឯកឧត្តម**បានបញ្ជាក់ថា ត្រូវផ្តោតការយកចិត្តទុកដាក់អោយបានខ្លាំង លើបញ្ហាភាសាអង់គ្លេស

ព្រមទាំងលើកទឹកចិត្តអោយធ្វើការស្រាវជ្រាវឲ្យបានច្រើន ព្រោះការរៀនសូត្រទោះបីជារៀនមួយជីវិតក៏ចេះមិនអស់ដែរ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានផ្តល់ការផ្តាំផ្ញើនិងអនុសាសន៍ទៅនិស្សិតទាំង២៧រូបនោះ អោយយកចិត្តទុកដាក់ក្នុងការសិក្សាយកចំណេះវិជ្ជា និងបទពិសោធន៍ផ្សេងៗពីប្រទេសនូវែហ្សេឡង់ ត្រូវបង្កើនទំនាក់ទំនងជាមួយនិស្សិតផ្សេងៗទៀត និងប្រជាជននូវែហ្សេឡង់ ហើយនិងថែរក្សាកិត្តិយសរបស់ខ្លួននិងរបស់ប្រទេសជាតិ។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសំដែងនូវក្តីសង្ឃឹមដោយជឿជាក់ថា និស្សិតទាំង២៧រូប នឹងសម្រេចការសិក្សាដោយជោគជ័យ ហើយក្លាយជាអ្នកបន្តវេនក្នុងការងារសំខាន់ៗជាច្រើន នៅថ្ងៃអនាគត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជាដំណឹងដល់និស្សិតទាំងអស់ពីការបាត់បង់ជីវិតរបស់កងកំលាំងថែរក្សាសន្តិភាពរបស់កម្ពុជាចំនួន២រូប ដោយសារជំងឺក្នុងពេលបំពេញបេសកកម្មនៅបរទេស (១នាក់នៅប្រទេសម៉ាលី និងម្នាក់ទៀតនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល) ដែលជាឧទាហរណ៍ជាក់ស្តែង សម្រាប់ទាក់ទាញការប្រុងប្រយ័ត្នរបស់និស្សិតចំពោះការថែរក្សាសុខភាព។

បន្ទាប់ពីស្តាប់មតិណែនាំ និងអនុសាសន៍របស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** លោក សេង សំអូន តំណាងនិស្សិតទាំង ២៧ ក៏បានធ្វើការចាប់អារម្មណ៍ និងសម្តែងអំណរគុណដល់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដែលបានចែករំលែកនូវបទពិសោធន៍របស់ឯកឧត្តមផ្ទាល់ ក៏ដូចជាការផ្តាំផ្ញើរនិងអនុសាសន៍សំខាន់ៗមួយចំនួន ដើម្បីនិស្សិតសម្រេចបានជោគជ័យក្នុងការសិក្សានៅក្រៅប្រទេស។

នៅចុងបញ្ចប់នៃពិធីសំណេះសំណាលនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានឧបត្ថម្ភជាថវិកាមួយចំនួនដល់និស្សិតទាំង២៧រូបនេះ ផងដែរ៕

ភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៧